ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ១៣១/១១-ហ្គូដ ភីភីល
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១១

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

**សមាសភាពក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ លីវ សុវណ្ណា
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

**ភាគីនៃវិវាទ**

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ហ្គូដ ភីភីល (ខេមបូឌា) អិលធីឌី**
អាសយដ្ឋាន ៖ ភូមិត្រពាំងញ្ញា សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១២ ២១៤ ២៣៤ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជក ៖

| | |
|---|---|
| ១- លោក Kang Mun Won | នាយក្រុមហ៊ុន |
| ២- លោក Mun Hee Chol | អ្នកបកប្រែ |
| ៣- លោក Uth Sophanarith | រដ្ឋបាល |
| ៤- លោក Cheath Monika | ប្រធានគ្រប់គ្រងផ្នែកទំនិញចេញ-ចូល |
| ៥- លោក Cheath Khemara | មន្ត្រី GMAC |

**២- ភាគីកម្មករនិយោជិត**

ក/-ឈ្មោះ ៖ **សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ**
អាសយដ្ឋាន ៖ ផ្ទះលេខ ១៨ DF ផ្លូវ ៤ KD សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ

ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh• Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org• Website: www.arbitrationcouncil.org

ទូរស័ព្ទ ៖ ០១៧ ៤៣០ ៣១២ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖ **អវត្តមាន**

ខ/-ឈ្មោះ ៖ **សមាគមជាតិកម្ពុជាការពារកម្មករ**

អាសយដ្ឋាន ៖ ភូមិត្រពាំងឈូ សង្កាត់កាកាប ខណ្ឌដង្កោ រាជធានីភ្នំពេញ

ទូរស័ព្ទ ៖ ០៨៩ ៦៨៦ ៧៦៨ ទូរសារ ៖ គ្មាន

តំណាងកម្មករនិយោជិត ៖

| | |
|---|---|
| ១- លោក សៀង ណារិទ្ធិ | អនុប្រធានសហព័ន្ធសហជីព CWEF |
| ២- លោក អ៊ុន ដារា | ប្រធានសហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ |
| ៣- លោក រីម ថារិទ្ធ | អនុប្រធានសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា |
| ៤- កញ្ញា ផន ម៉ៃ | កម្មករ |
| ៥- កញ្ញា ឈឹម ស្រីមាន | កម្មករ |
| ៦- កញ្ញា គិច ចាន់រតនី | កម្មករ |
| ៧- កញ្ញា សោម ដាវី | កម្មករ |
| ៨- កញ្ញា សុខ រ៉ន | កម្មករ |
| ៩- កញ្ញា វ៉ង់ ឡាង | កម្មករ |
| ១០- កញ្ញា ស៊ុំ សុខឃៀន | កម្មករ |
| ១១- កញ្ញា អ៊ិន សុផល | កម្មករ |

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- ចំពោះកម្មករនិយោជិត ដែលធ្វើការលើសពីពីរខែ សូមឱ្យបញ្ចូលជាកម្មករពេញសិទ្ធិ ។

២- សូមឱ្យក្រុមហ៊ុនអនុញ្ញាតឱ្យស្ត្រីមានផ្ទៃពោះបានទៅពិនិត្យសុខភាពក្នុងមួយខែម្តង ដោយរក្សាប្រាក់ឈ្នួល និងប្រាក់រង្វាន់ ។

៣- សូមឱ្យក្រុមហ៊ុនតម្លើងប្រាក់ឈ្នួលគោលជូនកម្មករនិយោជិតទាំងអស់ឱ្យបាន ៦៥ ដុល្លារក្នុងមួយខែ ។

៤- សូមឱ្យក្រុមហ៊ុនរៀបចំឱ្យកម្មករបានថែមម៉ោងស្មើៗគ្នា ។

៥- សូមកុំឱ្យក្រុមហ៊ុនប្រើកម្មករជំនាញទៅធ្វើអនាម័យនៅតាមក្រុម ។

៦- សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់ធ្វើការទៀងទាត់ឱ្យកម្មករចំនួន ១០ ដុល្លារមួយខែ ។

៧- នៅពេលកម្មករនិយោជិតដេរដល់ចំនួនកំណត់ សូមឱ្យក្រុមហ៊ុនផ្តល់ប្រាក់រង្វាន់លើកទឹកចិត្តចំនួន ១០ ដុល្លារជូនកម្មករ ។

៨- នៅពេលកម្មករមានធុរៈសុំច្បាប់ឈប់សម្រាក សូមឱ្យក្រុមហ៊ុនរក្សាប្រាក់រង្វាន់ទៀងទាត់នៅដដែល ។

៩- សូមឱ្យក្រុមហ៊ុនដករដ្ឋបាលដែលតែងតែប្រើពាក្យសំដី និងអាកប្បកិរិយាមិនសមរម្យមកលើកម្មករ ។

១០- សូមឱ្យក្រុមហ៊ុនរៀបចំឱ្យកម្មករនិយោជិតបានទៅពិនិត្យសុខភាព ការចំណាយផ្សេងៗជាបន្ទុករបស់ក្រុមហ៊ុន ។

១១- សូមឱ្យក្រុមហ៊ុនអនុវត្តកិច្ចសន្យាមានរយៈពេលចាប់ពី ៦ ខែឡើងទៅ ។

១២- ចំពោះកម្មករនិយោជិតដែលបានធ្វើកូដកម្មចាប់ពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១១ សូមឱ្យក្រុមហ៊ុនរក្សាប្រាក់ឈ្នួលនៅដដែល ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៣៦ កប/ប្រក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ (អាណត្តិទី៥) ។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី ១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជា នឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការមិនសះជាលេខ ១១៣៤ កប/អក/វក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ (វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក) ។

**បញ្ហានៃនីតិវិធី ៖**

នៅថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១ កម្មករនិយោជិតប្រមាណជាង ១០០ នាក់ ដឹកនាំដោយសហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ និងសហព័ន្ធសហជីពអំណាចកម្មករខ្មែរ ដែលជាសមាជិកមួយផងដែររបស់សហភាពជាតិកម្ពុជាការពារកម្មករបានធ្វើកូដកម្ម ដើម្បីទាមទារឱ្យក្រុមហ៊ុនកែលំអរទូវលក្ខខណ្ឌការងារមួយចំនួន ១២ ចំណុច។ បន្ទាប់ពីបានព័ត៌មានកូដកម្មនេះភ្លាម នាយកដ្ឋានវិវាទការងារបានចាត់មន្ត្រីជំនាញធ្វើការផ្សះផ្សាវិវាទការងារនេះដល់ទីតាំងរោងចក្រ ប៉ុន្តែ ភាគីកម្មករនិយោជិត និងភាគីក្រុមហ៊ុនមិនឯកភាពធ្វើការចរចាទេ ដោយភាគីក្រុមហ៊ុនលើកឡើងថា ក្រុមហ៊ុនធ្វើការចរចារតែជាមួយតំណាងកម្មករនិយោជិតប្រចាំក្រុមហ៊ុនផ្ទាល់ ពីព្រោះនៅក្នុងក្រុមហ៊ុនមិន

ទាន់មានសហជីពនៅឡើយ។ ចំណែកឯភាគីកម្មករនិយោជិតចង់ឱ្យមានការចរចាដោយមានការចូលរួមពីសហព័ន្ធសហជីពរួចរាល់សិន ទើបចូលធ្វើការងារវិញ។ ហេតុនេះ នៅរសៀលថ្ងៃដដែល មន្ត្រីជំនាញនាយកដ្ឋានវិវាទការងារបានបន្តធ្វើការផ្សះផ្សាទៀត ប៉ុន្តែ នៅតែមិនទទួលបានលទ្ធផលសះជានឹងគ្នាលើចំណុចទាំង ១២ ដដែល។ ចំណុចមិនសះជាចំនួន ១២ ចំណុចនេះ បានបញ្ជូនមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ តាមរយៈរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ហ្គូដ ភីភល (ខេមបូឌា) អិលធីឌី លេខ ១១៣៤ កប/អក/វក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

បន្ទាប់ពីបានទទួលសំណុំរឿងរួចមក ដោយសារតែការធ្វើកូដកម្មនៅតែបន្ត និងយោងតាមសំណើររបស់ក្រុមហ៊ុន ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១ សុំជួយអន្តរាគមន៍ ដើម្បីឱ្យកម្មករនិយោជិតចូលធ្វើការវិញនោះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានចេញសេចក្តីបញ្ជាលេខ ០១៤/១១ កបអ ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១១ ឱ្យផ្អាកជាបន្ទាន់ការធ្វើកូដកម្មរបស់កម្មករនិយោជិតនៅក្រុមហ៊ុន ហ្គូដ ភីភល (ខេមបូឌា) អិលធីឌី រហូតដល់នីតិវិធីនៃអាជ្ញាកណ្តាលត្រូវបានចប់សព្វគ្រប់តាមនីតិវិធីច្បាប់ ហើយកូដករទាំងអស់ត្រូវត្រឡប់ចូលធ្វើការវិញ ចាប់ពីថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១ តទៅ តាមវេនរបស់ខ្លួន។

ភាគីកម្មករនិយោជិត ដែលជាកូដករបានគោរពទៅតាមសេចក្តីបញ្ជាក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ហេតុនេះ លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានធ្វើការកោះអញ្ជើញ ភាគីនិយោជក និងភាគីកម្មករនិយោជិតប្រចាំរោងចក្រមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជាចំនួន ១២ ចំណុចនេះ នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ០៨ និង ៣០ នាទី ព្រឹក។

នៅថ្ងៃសវនាការ ភាគីនិយោជកបានមកចូលរួមសវនាការតាមការកោះហៅរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ចំពោះភាគីកម្មករនិយោជិតវិញ គឺមានតែសហជីពសេដ្ឋកិច្ចកម្មករកម្ពុជា សហព័ន្ធសហជីពស្មារតីកម្មករឯករាជ្យ និងសហព័ន្ធសហជីពសាមគ្គីភាពការងារកម្ពុជា ដែលត្រូវបានចាត់ដោយសហភាពជាតិកម្ពុជាការពារកម្មករបានមកចូលរួមសវនាការ និងបានសម្រេចដកពាក្យបណ្តឹងចេញពីការទាមទារនៅក្នុងសំណុំរឿងនេះ។ ដោយឡែកសហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ ដែលជាភាគីដើមបណ្តឹងនៅក្នុងសំណុំរឿងនេះផងដែរនោះ មិនបានមកចូលរួមសវនាការតាមការអញ្ជើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលទេ (អវត្តមាននៅថ្ងៃសវនាការ) ដោយគ្មានបញ្ជាក់មូលហេតុត្រឹមត្រូវ។

ហេតុនេះហើយ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណា និងសម្រេច ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតបញ្ជាក់នាមករណ៍របស់ក្រុមហ៊ុន ហ្គូដ ភីភីល លេខ ១៦៧៥ ពណ.ចបព ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ ២០១១ ។

២- លក្ខន្តិកៈក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ ២០១១ ។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ ២០១១ ។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១-របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ហ្គូដ ភីភីល លេខ ១១៣៤ កប/អក/វក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១១។

២-កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមរបស់ក្រុមហ៊ុន ហ្គូដ ភីភីល ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០១១

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១-លិខិតអញ្ជើញនិយោជកចូលរួមសវនាការលេខ ៧៣១ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ ២០១១។

២-លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការលេខ ៧៣២ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។

**អង្គហេតុ**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនអាចរកឃើញអង្គហេតុ ទាក់ទងនឹងការទាមទារនៅក្នុងសំណុំរឿងនេះទេ ដោយហេតុថា សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ ដែលភាគីដើមបណ្តឹងមួយក្នុងចំណោមដើមបណ្តឹងផ្សេងទៀត បានអវត្តមាននៅថ្ងៃសវនាការ ដោយគ្មានបញ្ជាក់មូលហេតុត្រឹមត្រូវ។

**ហេតុផលនៃសេចក្តីសម្រេច ÷**

នៅក្នុងសំណុំរឿងនេះ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករមិនបានចូលរួមនៅក្នុងនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលតាមការអញ្ជើញទេ។ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករគ្រាន់តែបានជូនដំណឹងមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃសវនាការតែម្តងថា មិនបានចូលរួមសវនាការទេ ដោយមានការរវល់។ពោល គឺមិនបានបញ្ជាក់ពីមូលហេតុត្រឹមត្រូវពីការមិនមកចូលរួមសវនាការនេះទេ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាលើសំណុំរឿងនេះ ដូចខាងក្រោម ៖

ប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល ប្រការ ២១ ចែងថា *"ក្នុងករណីភាគីណាមួយបានទទួលការអញ្ជើញត្រឹមត្រូវហើយ តែបែរជាខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល ដោយគ្មានបង្ហាញមូលហេតុត្រឹមត្រូវ ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងពេលដែលភាគីនោះអវត្តមាន ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាលដោយចេញជាសេចក្តីបង្គាប់"* ។

វិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ. ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ ចែងថា *"ប្រសិនបើភាគីណាមួយមិនបានបង្ហាញខ្លួន ឬមិនមានអ្នកតំណាងក្នុងដំណើរការ*

*អាជ្ញាកណ្តាល ក្រុមអាជ្ញាកណ្តាលអាចបន្តដំណើរការរបស់ខ្លួនក្នុងអវត្តមានរបស់ភាគីនោះ ឬអាចបញ្ចប់ដំណើរការអាជ្ញាកណ្តាល ដោយចេញជាសេចក្តីបង្គាប់...*" ។

នៅក្នុងសំណុំរឿងលេខ ១៦/០៧-ឡូទូសតី និងលេខ ២៧/០៧-អ៊ីម និង រ៉េ ៣ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយប្រការ ២១ ខាងលើនេះថា មានលក្ខខណ្ឌបី ដែលត្រូវបំពេញ ដើម្បីឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងបាន "*លក្ខខណ្ឌទី១ ៖ ភាគីត្រូវបានជូនដំណឹងដោយត្រឹមត្រូវ លក្ខខណ្ឌទី២ ៖ ភាគីមិនបានបង្ហាញខ្លួននៅក្នុងសវនាការ និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន*" ។

យោងតាមវិធាន ៤.៧ នៃវិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ឧបសម្ព័ន្ធនៃប្រកាសលេខ ០៩៩ សកបយ ប្រការ ២១ នៃប្រកាសលេខ ០៩៩ សកបយ និងការយល់ឃើញរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុន១ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងសំណុំរឿងនេះ យល់ឃើញថា ក្រុមអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងទៅតាមលក្ខខណ្ឌទាំងបីនោះ គឺ លក្ខខណ្ឌទី១ ៖ ភាគីបានទទួលការអញ្ជើញត្រឹមត្រូវ លក្ខខណ្ឌទី២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល និងលក្ខខណ្ឌទី៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន។

ហេតុនេះហើយ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើលក្ខខណ្ឌទាំងបីនេះ ត្រូវបានបំពេញដែរ ឬទេ?

**លក្ខខណ្ឌទី ១ ៖ ភាគីត្រូវបានទទួលការអញ្ជើញត្រឹមត្រូវ**

មន្ត្រីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញសហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មកចូលរួមសវនាការអាជ្ញាកណ្តាលត្រឹមត្រូវ តាមរយៈលិខិតអញ្ជើញលេខ ៧៣២ កប/អក/វក/លកអ. ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១១។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ ពិតជាទទួលបានការអញ្ជើញត្រឹមត្រូវពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ឱ្យមកចូលរួមសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិតប្រាកដមែន។ ហេតុនេះ លក្ខខណ្ឌទី ១ ត្រូវបានបំពេញ។

**លក្ខខណ្ឌទី ២ ៖ ភាគីខកខានមិនបានមកបង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ពាក្យ "បង្ហាញខ្លួននៅចំពោះមុខក្រុមអាជ្ញាកណ្តាល" នៅក្នុងប្រការ ២១ នៃប្រកាស លេខ ០៩៩ សកបយ ខាងលើ មានន័យថា ភាគីត្រូវតែចូលរួមដំណើរការសវនាការអាជ្ញាកណ្តាល តាំងពីដើមរហូតដល់ចប់សព្វគ្រប់។

ដំណើរការសវនាការអាជ្ញាកណ្តាល ដែលមានបួនដំណាក់កាល ដូចជា:

ក-ដំណាក់កាលណែនាំខ្លួន និងពន្យល់អំពីទំនាស់ផលប្រយោជន៍

ខ-ដំណាក់កាលពន្យល់អំពីនីតិវិធី និងបញ្ជាក់បញ្ហានៃវិវាទ

គ-ដំណាក់កាលផ្សះផ្សា បើភាគីយល់ព្រមឱ្យក្រុមប្រឹក្សាអាជ្ញាកណ្តាលផ្សះផ្សាឡើងវិញ

ឃ-និងដំណាក់កាលសវនាការដល់អង្គសេចក្តី

ក្នុងករណីនេះ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មិនបានចូលរួមនៅគ្រប់ដំណាក់កាលទាំងអស់នៃនីតិវិធីរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មិនបានបង្ហាញខ្លួននៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល តាមខ្លឹមសារនៃលក្ខខណ្ឌទី២ នៃប្រការ ២១ ខាងលើនេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី ២ ក៏ត្រូវបានបំពេញដែរ។

លក្ខខណ្ឌទី ៣ ៖ ភាគីមិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួន

ក្នុងករណីនេះ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មិនបានផ្តល់ហេតុផលណាមួយសម្រាប់ការមិនចូលរួមសវនាការនេះទេ។ ពោល គឺសហព័ន្ធសហជីពនេះ គ្រាន់តែបានជូនដំណឹងមកលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃសវនាការតែម្តង ថាមិនបានចូលរួមសវនាការទេ ដោយមានការរវល់។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មិនបានផ្តល់មូលហេតុត្រឹមត្រូវសម្រាប់ការមិនបង្ហាញខ្លួននេះទេ។ ហេតុនេះហើយ លក្ខខណ្ឌទី៣ ក៏ត្រូវបានបំពេញដែរ។

ដូច្នេះ ជាសរុបមក លក្ខខណ្ឌទាំងបីដែលមានចែងក្នុងប្រការ ២១ ខាងលើ ត្រូវបានបំពេញ។

បន្ថែមពីលើនេះទៀត នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានផ្តល់ឱកាសគ្រប់គ្រាន់ដល់សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ ដែលជាភាគីដើមបណ្តឹង ក្នុងការធ្វើការការពារចំពោះការទាមទាររបស់កម្មករនិយោជិតដែលពឹងពាក់ខ្លួនតាមនីតិវិធីច្បាប់ស្តីពីការងារ។ ប៉ុន្តែ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ បានជ្រើសរើសយកការមិនចូលរួមនៅក្នុងដំណើរការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ មានចេតនាមិនចូលរួមដោះស្រាយជម្លោះរបស់ខ្លួនជាមួយនិយោជកតាមនីតិវិធីដែលច្បាប់តម្រូវនោះឡើយ។

ជាទូទៅ ដើមបណ្តឹងមានកាតព្វកិច្ចផ្តល់ហេតុផល និងភស្តុតាងនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីការពារបណ្តឹងរបស់ខ្លួន។ ប៉ុន្តែ ក្នុងសំណុំរឿងនេះ សហព័ន្ធសហជីពសិទ្ធិប្រយោជន៍កម្មករ ដែលជាភាគីដើមបណ្តឹងមិនបានផ្តល់នូវហេតុផល និងភស្តុតាង ដើម្បីការពារបណ្តឹងរបស់ខ្លួនទេ។ ក្នុងករណីភាគីដើមបណ្តឹងមិនចូលរួមក្នុងសវនាការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល វាជាហេតុធ្វើឱ្យភាគីបាត់បង់ឱកាសក្នុងការផ្តល់ហេតុផល និងភស្តុតាង ដើម្បីការពារ និងគាំទ្រការទាមទាររបស់ខ្លួន។ ក្រុមប្រឹក្សាអាជ្ញាកណ្តាលចាត់ទុកថា នេះជាការបោះបង់បណ្តឹងរបស់ខ្លួន។ ការសម្រេចចិត្តបែបនេះ គឺមិនបានបង្ហាញពីសុឆន្ទៈដោយសុទ្ធចិត្តក្នុងការយកវិវាទការងាររបស់ខ្លួនមកដោះស្រាយនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលនោះឡើយ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចបិទសំណុំរឿងលេខ ១៣១/១១-ហ្គូដ ភីភីល នេះ។

យោងតាមអង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ដូចតទៅ ៖

## សម្រេច និង បង្គាប់

- បិទសំណុំរឿងលេខ ១៣១/១១-ហ្គូដ ភីភីល។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា: ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **លីវ សុវណ្ណា**

ហត្ថលេខា: ------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា: ------------------------------

ARBITRATION COUNCIL